មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

## សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទជាអនីតិជន

www.cchrcambodia.org
លេខ១៤ : ខែ វិច្ឆិកា ឆ្នាំ២០២១

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានធ្វើការសង្កេតការណ៍សវនាការចាប់ពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌនៅតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តការជំនុំជម្រះដោយយុត្តិធម៌តាមបទដ្ឋានជាតិ និងអន្តរជាតិ។ ចាប់តាំងពីខែមីនា ឆ្នាំ២០១៣ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក បានសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ។

ព្រឹត្តិបត្រព័ត៌មាននេះគឺជាផ្នែកនៃការចេញផ្សាយជាសេរី ដែលវិភាគលើរបកគំហើញពីការសង្កេតការណ៍សវនាការរបស់ម.ស.ម.ក និងពិភាក្សាបញ្ហានានាឱ្យកាន់តែទូលំទូលាយ។ ព្រឹត្តិបត្រព័ត៌មាននេះផ្តោតលើសិទ្ធិរបស់ជនជាប់ចោទជាអនីតិជន ជាពិសេសសិទ្ធិឯកជនភាព សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងការឃុំខ្លួនបណ្តោះអាសន្ន។

ទិន្នន័យទាំងអស់ដែលបានប្រមូលដោយ ម.ស.ម.ក នៅអំឡុងពេលសង្កេតការណ៍សវនាការ អាចស្វែងរកបាននៅប្រព័ន្ធផ្ទុកទិន្នន័យសង្កេតការណ៍សវនាការរបស់យើង។

### សិទ្ធិរបស់ជនជាប់ចោទជាអនីតិជន

*តើមាននីតិវិធីអ្វីកើតឡើង ប្រសិនបើអនីតិជនត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ?*

អនីតិជនរងការចោទប្រកាន់ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដូចគ្នានឹងនីតិជនដែរ។ ទោះបីជាយ៉ាងនេះក្តី ពួកគេក៏ទទួលបានកិច្ចការពារបន្ថែម ដោយសារតែអាយុ ភាពដឹងក្តី និងការអភិវឌ្ឍផ្នែកប្រាជ្ញារបស់ពួកគេ។ ទាំងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិចែងអំពីការប្រព្រឹត្តជាពិសេសទៅលើអនីតិជន។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក") បានចែងពីបញ្ញត្តិជាក់លាក់សម្រាប់ការប្រព្រឹត្តទៅលើអនីតិជននៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ បញ្ញត្តិទាំងនេះរួមបញ្ចូលនូវនីតិវិធីត្រូវតែធ្វើឡើង ដោយពិចារណាទៅលើអាយុរបស់កុមារ និងលើកកម្ពស់ការពារអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ(មាត្រា ១៤(៤) នៃ ក.អ.ស.ព.ន)។ បន្ថែមលើនេះ ការរស់រាន និងការអភិវឌ្ឍរបស់កុមារត្រូវតែធានានៅក្នុងកម្រិតអតិបរមា (មាត្រា៦(២) នៃ អ.ស.ក)។

ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន នៅឆ្នាំ២០១៦ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ជាក់ស្តែង ការសាកសួរដេញដោលសាក្សី និងជនជាប់ចោទ ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ដែលមិនអនុញ្ញាតឱ្យសាធារណជនចូលរួមស្តាប់

**អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣(១)**

*"នៅក្នុងវិធានការទាំងអស់ ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈ ទទួលភារៈខាងសុខុមាលភាពសង្គម ដោយតុលាការ ឬដោយអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ **ផលប្រយោជន៍ល្អបំផុតរបស់កុមារ ត្រូវតែយកចិត្តទុកដាក់ជាមុន**។"*

**ច្បាប់កម្ពុជាស្តីពីយុត្តិធម៌អនីតិជន**
**មាត្រា៥**

*"គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ ត្រូវយកចិត្តទុកដាក់ និង **ពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា** [...]"*

ដើម្បីគោរពសិទ្ធិឯកជនភាពរបស់អនីតិជន (មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន)។

> "ការពិភាក្សាដេញដោលនិងការប្រកាសសាលក្រមរឿងក្តីអនីតិជនត្រូវធ្វើឡើងក្នុងសវនាការអសាធារណៈ [...]" *មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន*

បន្ថែមលើនេះ អនីតិជនរងការចោទប្រកាន់ត្រូវបានសន្មតទុកជាមុនថាគ្មានទោស រហូតដល់មានការបង្ហាញពីពិរុទ្ធភាព ហើយការឃុំខ្លួនបណ្តោះអាសន្នរបស់ពួកគេគួរជៀសវាងនៅក្នុងកម្រិតខ្ពស់បំផុតដែលអាចធ្វើបាន។ (មាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន)។

### *សិទ្ធិឯកជនភាព*

> "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [...] សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន [...]" *មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន*

សិទ្ធិឯកជនភាពរបស់អនីតិជន ត្រូវធានានៅគ្រប់ដំណាក់កាលនីតិវិធីច្បាប់ទាំងអស់។ ហេតុផលជាមូលដ្ឋាននេះគឺដើម្បីជៀសវាងការធ្វើឱ្យប៉ះពាល់ដែលបណ្តាលមកពីការផ្សព្វផ្សាយជាសាធារណៈ ឬការសរសេរបង្កាច់កេរ្តិ៍មិនត្រឹមត្រូវ។ សិទ្ធិនេះមានចែងនៅមាត្រា ៥, ៦, ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏ដូចជាមាត្រា ៤០(២)(vii) នៃ អ.ស.ក។ ហេតុដូចនេះ មិនមានព័ត៌មានណាមួយគួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដែលអាចនាំឱ្យមានការបង្ហាញ

CC BY NC SA

អត្តសញ្ញាណរបស់កុមារ។[1] សិទ្ធិឯកជនភាពអនុវត្តចាប់តាំងពីការទាក់ទងដំបូងនឹងការអនុវត្តច្បាប់ រហូតដល់សេចក្តីសម្រេចចូលជាស្ថាពរ ឬរហូតដល់កុមារត្រូវបានឱ្យរួចផុតពីការដាក់ស្ថិតក្រោមការត្រួតពិនិត្យ ការឃុំឃាំង ឬវិធានការផ្សេងទៀត ប្រសិនបើកុមារត្រូវបានផ្តន្ទាទោស។ នៅដំណាក់កាលជំនុំជម្រះ ឯកជនភាពរបស់អនីតិជនត្រូវបានការពារតាមរយៈ សវនាការជាអសាធាណៈ។

ឯកជនភាពរបស់អនីតិជន ក៏អាចត្រូវបានការពារដោយប្រើរបាំងការពារនៅអំឡុងពេលសវនាការ ឬប្រើប្រាស់មធ្យោបាយមួយចំនួនទៀតសម្រាប់ផ្តល់សក្ខីកម្ម (ដូចជាសវនាការតាមវីដេអូឆ្លើយឆ្លង ឬសវនាការជាអសាធារណៈ)។

## *សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស*

> "ក្នុងទិសដៅនេះ និងបទបញ្ញត្តិនៃលិខិតតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ រដ្ឋភាគីត្រូវធានា ជាពិសេសថាៈ [...] ចាត់ទុកកុមារថា ឥតទោសរហូតទាល់តែពិរុទ្ធភាព ត្រូវបានបង្ហាញស្របតាមច្បាប់" *មាត្រា ៤០(២)(i) នៃ អ.ស.ក*

នេះមានន័យថា អនីតិជនត្រូវបានសន្មតថាគ្មានទោសនៅក្នុងដំណើរការនីតិវិធីពេញទាំងមូល រហូតពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់។[2] នេះជាសិទ្ធិមូលដ្ឋាននិងទទួលស្គាល់ជាសាកល ដែលមានសារសំខាន់នៅគ្រប់ការជំនុំជម្រះដោយយុត្តិធម៌ទាំងមូល។ សិទ្ធិនេះមានចែងនៅក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងមាត្រា ១៤(២) នៃ ក.អ.ស.ព.ន និងមាត្រា៤០(២)(i) នៃ អ.ស.ក។

នៅក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃឆ្នាំ២០១៣ បានបង្គាប់ថា បុគ្គលដែលតុលាការមិនទាន់បានកាត់ទោស ឬការកាត់ទោសមិនទាន់ចូលជាស្ថាពរ ហើយដែលអ្នកទាំងនេះ ត្រូវអាជ្ញាធរឃុំខ្លួននឹងតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។
ខណៈ ការកំណត់ផ្សេងគ្នារវាងឯកសណ្ឋានសម្រាប់ទណ្ឌិត និងជនជាប់ឃុំដែលមិនទាន់មានសេចក្តីសម្រេចស្ថាពរជាកិច្ចគួរឱ្យស្វាគមន៍ក្តី ដើម្បីធានាថា សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ត្រូវបានគោរពយ៉ាងពេញលេញ ជនជាប់ចោទទាំងអស់ដែលមិនទាន់កាត់ទោសជាស្ថាពរគួរតែអាចស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួននៅពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

ការអនុវត្តជាអន្តរជាតិដ៏ល្អនៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌ ជាការកត់សម្គាល់នៅក្នុងវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ដែលអនុម័តនៅឆ្នាំ២០១៥[3] ចង្អុលបង្ហាញថា ជនជាប់ចោទគួរអាចស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួននៅពេលបង្ហាញខ្លួនចំពោះមុខតុលាការ។ បន្ថែមលើនេះ នៅអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួន គ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌទាំងអស់រហូតដល់ការកាត់ឱ្យជាប់ទោសចូលជាស្ថាពរ។

សម្រាប់ន័យនេះ ជនជាប់ចោទជាអនីតិជន ដែលការកាត់ឱ្យជាប់ទោសមិនទាន់ចូលជាស្ថាពរត្រូវបានការពារពីការស្លៀកពាក់ឯកសណ្ឋានទណ្ឌិតនៅអំឡុងពេលសវនាការ។[4]

បន្ថែមលើនេះ ក្នុងចំណោមគោលការណ៍ដទៃទៀត ការសន្មតទុកជាមុនថាគ្មានទោសតម្រូវឱ្យ៖

- តុលាការមិនត្រូវសម្រេចសេចក្តីលើសំណុំរឿងមុនសវនាការនោះទេ
- ការផ្តន្ទាទោសត្រូវតែបង្ហាញថាមានពិរុទ្ធភាពឱ្យហួសពីវិមតិសង្ស័យ (មានន័យថា នេះមិនមែនជាកាតព្វកិច្ចរបស់អនីតិជនក្នុងការបង្ហាញថាពួកគេមិនបានប្រព្រឹត្តបទល្មើស ដែលត្រូវបានចោទប្រកាន់មកលើខ្លួននោះទេ)
- អនីតិជនដែលរងការចោទប្រកាន់ មិនគួរត្រូវបានចាត់ទុកថាពួកគេមានពិរុទ្ធភាព នៅក្នុងដំណើរការនីតិវិធីនោះទេ
- ប្រព័ន្ធផ្សព្វផ្សាយគួរចៀសវាងការផ្សព្វផ្សាយព័ត៌មាន ដែលធ្វើឱ្យប៉ះពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោស ឧទាហរណ៍ ដូចជាតាមរយៈការបង្ហាញថា អនីតិជនមានពិរុទ្ធភាព និង
- អាជ្ញាធរសាធារណៈមិនត្រូវធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីបញ្ជាក់អះអាងពីពិរុទ្ធភាពរបស់ជនជាប់ចោទ។[5]

## *ការឃុំខ្លួនបណ្តោះអាសន្នជាជម្រើសចុងក្រោយ*

> "គ្មានកុមារណាម្នាក់ ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តឡើយ។ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារត្រូវធ្វើស្របតាមច្បាប់ និងត្រូវប្រើសម្រាប់តែវិធានការចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុត។" *មាត្រា ៣៧(ខ) នៃ អ.ស.ក*

ការដកហូតសេរីភាពទៅលើអនីតិជន ចាប់តាំងពីការចាប់ខ្លួនរហូតទៅដល់នីតិវិធីនៃការកាត់ទោស ត្រូវធ្វើឡើងសម្រាប់តែវិធានការចុងក្រោយ និងគួរតែប្រើសម្រាប់តែករណីពិសេសប៉ុណ្ណោះ និងសម្រាប់រយៈពេលសមរម្យខ្លីបំផុតដូចមានចែងនៅមាត្រា ៣៧(ខ) នៃ អ.ស.ក ព្រមទាំងមាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ[6] ចែងពីភាពចំបាច់នៃច្បាប់ ដើម្បីរួមបញ្ចូល និង ធ្វើជាអាទិភាពលើវិធានការមិនឃុំខ្លួនសម្រាប់អនីតិជនរងការចោទប្រកាន់ ដើម្បីជៀសវាងការដកហូតសេរីភាពរបស់ពួកគេ ក្នុងកម្រិតខ្ពស់ដែលអាចធ្វើទៅបាន។ ច្បាប់កម្ពុជាចែងអំពីវិធានការជំនួសចំពោះទោសពន្ធនាគារ។ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងថា អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃ

---

[1] សេចក្តីពន្យល់ទូទៅ អ.ស.ក លេខ១០ "សិទ្ធិរបស់កុមារនៅក្នុងយុត្តិធម៌អនីតិជន", ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧, កថាខណ្ឌ.៦៤, https://www2.ohchr.org/english/bodies/crc/docs/CRC.C.GC.10.pdf ។

[2] ការិយាល័យឧត្តមស្នងការ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ភាគ១ ជំពូក៦ ទំព័រ ២១៩ https://www.ohchr.org/Documents/Publications/training9chapter6en.pdf ។

[3] មហាសន្និបាត អ.ប.ជ "វិធានអង្គការសហប្រជាជាតិស្តីពី បទដ្ឋានអប្បបរមា សម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ" ៧០/១៧៥, ឧបសម្ពន្ធ័ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥, https://bit.ly/3iXTqJB ។

[4] ឯកសណ្ឋានទណ្ឌិតសំដៅដល់សម្លៀកបំពាក់ពណ៌ខៀវឆ្នូតស។

[5] UN HRC សេចក្តីពន្យល់ទូទៅលេខ៣២ "មាត្រា១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ៣០ https://bit.ly/2FB9fEh។

[6] UN HRC សេចក្តីពន្យល់ទូទៅលេខ២៤ ឆ្នាំ២០១៩ "យុត្តិធម៌អនីតិជននៅក្នុងសិទ្ធិកុមារ" កថាខណ្ឌទី៧៣ https://bit.ly/3CDzkf5 ។

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ហើយ មាត្រា ៤០ ចែងអំពីបញ្ជីរៀបរាប់ពីវិធានការត្រួតពិនិត្យ អប់រំ ការពារ និងឧបត្ថម្ភ ដើម្បីអនុវត្តទៅលើអនីតិជន។

គួរកត់សម្គាល់ វិធានការបែបនេះរួមបញ្ចូលទាំងការប្រគល់អនីតិជនឱ្យទៅ ឪពុកម្ដាយរបស់ពួកគេ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ការប្រគល់ឱ្យទៅទីភ្នាក់ងារសេវាសាធារណៈមានសមត្ថកិច្ច អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬស្ថាប័នឯកទេស ព្រមទាំងការឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

### *តើមាននីតិវិធីអ្វីកើតឡើង នៅពេលដែលអនីតិជនត្រូវបានផ្ដន្ទាទោសក្នុងរឿងព្រហ្មទណ្ឌ?*

ឧត្តមប្រយោជន៍របស់កុមារត្រូវតែយកចិត្តទុកដាក់ជាចម្បងនៅពេលដែលមានការបង្គាប់ឬការដាក់ទោសលើអនីតិជន ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ។ នេះយោងតាមមាត្រា ៣(១) នៃ អ.ស.ក។[7] ការជំនុំជម្រះរឿងក្ដីអនីតិជនត្រូវធ្វើឡើងនៅចំពោះមុខ“ទីប្រឹក្សាច្បាប់ ឬជំនួយសមស្របផ្សេងទៀត” និងឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ (ល្គឹកណាការអនុវត្តនេះមិនផ្ទុយពីឧត្តមប្រយោជន៍របស់កុមារ) (មាត្រា ៤០(២)(iii) នៃ អ.ស.ក)។

ការដាក់ទោសពន្ធនាគារទៅលើអនីតិជនត្រូវតែពិចារណាធ្វើឡើងសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ និងត្រូវបានប្រើសម្រាប់តែករណីពិសេសប៉ុណ្ណោះ (មាត្រា ៣៧(ខ) នៃ អ.ស.ក)។ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាគោរពតាមបទបញ្ញត្តិនេះ ដោយលើកកម្ពស់វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភជាជាងវិធានការឃុំខ្លួន។ ទោះជាយ៉ាងនេះក្ដី ប្រសិនបើ“កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ” តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបាន។

មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌកម្ពុជាក៏អនុញ្ញាតឱ្យមានវិធានការដទៃទៀតជំនួសទោសពន្ធនាគារ ដូចជាវិធានការការពារតាមផ្លូវតុលាការ ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ឬស្ថាប័ន ឬអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

## *សិទ្ធិរបស់ជនជាប់ចោទជាអនីតិជនជាតួលេខ*

### *របកគំហើញបានមកពីការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២០*

នៅចន្លោះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ម.ស.ម.ក បានសង្កេតការណ៍លើសំណុំរឿងចំនួន ២០៣ ដែលមានជនជាប់ចោទចំនួន ២៥៥ នាក់ នៅសាលាឧទ្ធរណ៍ភ្នំពេញ។ ក្នុងចំណោមសំណុំរឿងទាំងនេះ មានសំណុំរឿងចំនួន ១៥ ដែលមានជនជាប់ចោទជាអនីតិជនចំនួន ១៥ នាក់។ ជនជាប់ចោទជាអនីតិជនចំនួន ១៣ នាក់ ក្នុងចំណោម ១៥ នាក់ (៨៧%) មានអាយុចាប់ពី១៦ ឆ្នាំ ទៅដល់ ១៧ ឆ្នាំ នៅពេលបទល្មើសកើតឡើង និងជនជាប់ចោទជាអនីតិជនចំនួន ២ នាក់ (១៣%) មានអាយុ១៤ ឆ្នាំ ទៅដល់ ១៥ ឆ្នាំ នៅពេលបទល្មើសកើតឡើង។

ក្នុងចំណោមជនជាប់ចោទជាអនីតិជនពាក់ព័ន្ធនឹងសំណុំរឿង ដែលបានសង្កេតការណ៍ចំនួន ៩៣% (១៤ នាក់ ក្នុងចំណោម ១៥ នាក់) មានវត្តមាននៅពេលសវនាការ។ គ្រប់សវនាការទាំងអស់ត្រូវបានធ្វើឡើងជាសាធារណៈ និងមិនមានវិធានការណាមួយត្រូវបានប្រើប្រាស់ដោយតុលាការក្នុងការការពារឯកជនភាពរបស់ពួកគេឡើយ។




បន្ថែមលើនេះ សំណុំរឿងដែលបានសង្កេតការណ៍ទាក់ទងនឹងជនជាប់ចោទជាអនីតិជន ដែលត្រូវបានកាត់ឱ្យជាប់ទោសនៅសាលាដំបូង ប៉ុន្តែការដាក់ទោសរបស់ពួកគេកំពុងប្ដឹងឧទ្ធរណ៍ និងមិនទាន់ចូលជាស្ថាពរ។ បើទោះជាយ៉ាងនេះក្ដី ជនជាប់ចោទជាអនីតិជនចំនួន ៧៣% (១១ នាក់ ក្នុងចំណោម ១៥ នាក់) បានបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវ ខណៈពេលដែលជនជាប់ចោទជាអនីតិជនចំនួន ២០% (៣ នាក់ ក្នុងចំណោម ១៥ នាក់) បានបង្ហាញខ្លួនក្នុងឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ នៅពេលជាមួយគ្នានេះដែរ ជនជាប់ចោទជាអនីតិជនទាំងចំនួន ១៥ នាក់ (១០០%)ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។




* មិនពាក់ព័ន្ធ សំដៅដល់សំណុំរឿងដែលជនជាប់ចោទជាអនីតិជនមិនត្រូវបានឃុំខ្លួន ឬអវត្តមាន

[7] សូមមើលសេចក្ដីពន្យល់ទូទៅលេខ១០ នៃ អ.ស.ក “សិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន” កថាខណ្ឌ ១០ និង៧១ ដែលបានលើកយកមកនៅលេខយោងទី១ ខាងលើ។

CC BY NC SA

សម្រាប់ជនជាប់ចោទ ដែលការកាត់ឱ្យជាប់ទោសរបស់ពួកគេមិនទាន់ចូលជាស្ថាពរ ការមិនចាត់វិធានការសម្រាប់ការការពារឯកជនភាពនៅអំឡុងពេលសវនាការ ការតម្រូវឱ្យអនីតិជនរងការចោទប្រកាន់ស្លៀកពាក់ឯកសណ្ឋានទណ្ឌិតបង្ហាញខ្លួនចំពោះមុខតុលាការ និងការឃុំខ្លួនពួកគេបណ្ដោះអាសន្ន គឺមិនស្របច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិ ដែលបានលើកឡើងនៅផ្នែកមុននិងបទដ្ឋានអន្តរជាតិ ដូចជាបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ជាដើម។

### *ការវិវត្តនៃសិទ្ធិរបស់ជនជាប់ចោទជាអនីតិជន(ឆ្នាំ២០១៨-២០២០)*

| | សំណុំរឿងដែលបានសង្កេតការណ៍ | សំណុំរឿងទាក់ទងនឹងអនីតិជន | ចំនួនជនជាប់ចោទ | ចំនួនជនជាប់ចោទជាអនីតិជន |
|---|---|---|---|---|
| ១ វិច្ឆិកា ឆ្នាំ ២០១៨ ដល់ ៣១ តុលា ឆ្នាំ ២០១៩ | ២៣៩ | ១៤ (៥,៨%) | ៣៥២ | ២២ (៦,៣%) |
| ១ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ ៣១ ធ្នូ ឆ្នាំ ២០២០ | ២០៣ | ១៥ (៧,៣%) | ២៥៥ | ១៥ (៥,៨%) |
| ១ វិច្ឆិកា ឆ្នាំ ២០១៨ ដល់ ៣១ ធ្នូ ឆ្នាំ ២០២០ | ៤៤២ | ២៩ (៦,៦%) | ៦០៧ | ៣៧ (៦,១%) |

បើប្រៀបធៀបទៅអំឡុងឆ្នាំ២០១៩ ដល់ ឆ្នាំ២០២០ នៅចន្លោះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ និង ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ម.ស.ម.ក បានសង្កេតការណ៍លើសំណុំរឿងចំនួន ១៤ ពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជនក្នុងចំណោមសំណុំរឿងចំនួន ២៣៩ នៅសាលាឧទ្ធរណ៍ភ្នំពេញ។ សំណុំរឿងទាំងនេះ មានជនជាប់ចោទជាអនីតិជនចំនួន ២២ នាក់។ នៅពេលបទល្មើសកើតឡើង ជនជាប់ចោទជាអនីតិជនចំនួន ១៧ នាក់ ក្នុងចំណោមពួកគេទាំងអស់មានអាយុចាប់ពី ១៦ឆ្នាំ ដល់ ១៧ ឆ្នាំ (៧៧%) ៤ នាក់ មានអាយុចាប់ពី១៤ ឆ្នាំ ទៅដល់ ១៥ ឆ្នាំ (១៩%) និង ០១ នាក់ មានអាយុក្រោម១៤ ឆ្នាំ ប៉ុន្តែត្រូវបានឱ្យរួចផុតពីបទចោទភ្លាមៗដោយចៅក្រម ដោយយោងទៅតាមបទដ្ឋានសិទ្ធិមនុស្ស។ ក្នុងចំណោមជនជាប់ចោទជាអនីតិជនទាំងនោះ ជនជាប់ចោទជាអនីតិជនចំនួន ៨៦% (១៩ នាក់ ក្នុងចំណោម ២២ នាក់) ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន និង ចំនួន ៨២% (១៨ នាក់ ក្នុងចំណោម ២២ នាក់) មានវត្តមាននៅពេលសវនាការ។ ក្នុងចំណោមជនជាប់ចោទជាអនីតិជនទាំងនោះ ជនជាប់ចោទជាអនីតិជនចំនួន ៦៨% (១៥ នាក់ ក្នុងចំណោម ២២ នាក់) បានបង្ហាញខ្លួនចំពោះមុខតុលាការដោយស្លៀកពាក់ឯកសណ្ឋានទណ្ឌិតពណ៌ខៀវ ដែលរំលោភបំពានលើការសន្មតទុកជាមុនថាគ្មានទោស ខណៈដែលចំនួន ១៤% (៣ នាក់ ក្នុងចំណោម ២២ នាក់) ស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ បន្ថែមលើនេះ មិនមានវិធានការការពារសិទ្ធិឯកជនភាពរបស់ពួកគេនៅអំឡុងពេលសវនាការចំនួន ៦៨% (១៥ នាក់ ក្នុងចំណោម ២២ នាក់) ដែលរំលោភបំពានលើសិទ្ធិឯកជនភាពរបស់ពួកគេ។ ទោះបីជាយ៉ាងនេះក្ដី អ្វីដែលកត់សម្គាល់សំខាន់នោះគឺវិធានការពាក់ព័ន្ធត្រូវបានប្រើប្រាស់ក្នុងការការពារឯកជនភាពរបស់ជនជាប់ចោទជាអនីតិជនចំនួនបីនាក់ ដែលមានវត្តមាននៅពេលសវនាការ ដែលបង្ហាញពីការអនុវត្តដ៏ល្អ ដែលនេះគួរតែអនុវត្តនៅគ្រប់សំណុំរឿងទាំងអស់ទាក់ទងនឹងអនីតិជន។

ម.ស.ម.ក បានសង្កេតការណ៍លើសំណុំរឿងចំនួនតិចជាងមុន នៅឆ្នាំ២០១៩ ដល់ ឆ្នាំ២០២០ ហើយរបកគំហើញបង្ហាញថា សិទ្ធិរបស់ជនជាប់ចោទជាអនីតិជន ក៏ត្រូវបានគោរពដោយសាលាឧទ្ធរណ៍ភ្នំពេញតិចជាងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០១៨ ដល់ ឆ្នាំ២០១៩ ដែរ។ នេះជាភស្តុតាងជាក់ស្តែង ពាក់ព័ន្ធនឹងការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្ន និងកង្វះខាតការចាត់វិធានការការពារឯកជនភាពរបស់ជនជាប់ចោទជាអនីតិជន។

ជាសរុប ក្នុងចំណោមសំណុំរឿងចំនួន ២៩ ករណីជាប់ពាក់ព័ន្ធនឹងអនីតិជនចំនួន៣៧ នាក់ ដែល ម.ស.ម.ក បានសង្កេតការណ៍នៅអំឡុងឆ្នាំ២០១៨ ដល់ ឆ្នាំ២០២០ បង្ហាញពីអ្វីដែលគួរឲ្យបារម្ភមាន ទីមួយ ស្ទើរតែមិនមានវិធានការត្រូវបានប្រើប្រាស់ ដើម្បីគោរពឯកជនភាពរបស់ជនជាប់ចោទជាអនីតិជន។ តុលាការបានចាត់វិធានការណ៍ត្រឹមតែចំនួន ៨% ប៉ុណ្ណោះនៃជនជាប់ចោទជាអនីតិជន (៣នាក់ ក្នុងចំណោម ៣៧ នាក់) ជាប់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍។ ទីពីរ ជនជាប់ចោទជាអនីតិជនភាគច្រើនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ ជនជាប់ចោទជាអនីតិជនចំនួន ៩២% (៣៤ នាក់ ក្នុងចំណោម ៣៧ នាក់) ជាប់ពាក់ព័ន្ធនឹងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍បានរងចាំការជំនុំជម្រះនៅក្នុងឃុំខ្លួន។ ទីបី ជនជាប់ចោទជាអនីតិជនចំនួន ៧០% (២៦ នាក់ ក្នុងចំណោម ៣៧ នាក់) បានបង្ហាញខ្លួននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ ដោយស្លៀកពាក់ឯកសណ្ឋានទណ្ឌិតពណ៌ខៀវរីឯចំនួន ១៦% (៦ នាក់ ក្នុងចំណោម ៣៧ នាក់) ស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ មិនមានជនជាប់ចោទជាអនីតិជនណាម្នាក់បង្ហាញខ្លួននៅក្នុងតុលាការក្នុងសម្លៀកបំពាក់ផ្ទាល់ខ្លួនឡើយ បើទោះបីជាមានការផ្ដល់អនុសាសន៍នៃការអនុវត្តន៍ដ៏ល្អយ៉ាងណាក្ដី។

បញ្ហាជាច្រើនក្នុងចំណោមបញ្ហាទាំងនេះ និងជាពិសេស បញ្ហានៃសិទ្ធិឯកជនភាពរបស់អនីតិជន ត្រូវបានពិភាក្សាជាមួយប្រធានសាលាឧទ្ធរណ៍នៅខែសីហា ឆ្នាំ២០២០។[8] សាលាឧទ្ធរណ៍បានប្ដេជ្ញានឹងពិនិត្យមើលការអនុវត្តដែលមានមកហើយទាំងនេះដើម្បីអនុលោមតាមទាំងបទដ្ឋានជាតិ និងអន្តរជាតិ។

[8] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយប្រធាន និងក្រុមការងាររបស់សាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍ឆ្នាំ២០២០។










* មិនពាក់ព័ន្ធ សំដៅដល់សំណុំរឿងដែលជនជាប់ចោទជាអនីតិជនមិនត្រូវបានឃុំខ្លួន ឬ អវត្តមាន

## អនុសាសន៍

**ម.ស.ម.ក សូមអំពាវនាវដល់ចៅក្រម និងរាជរដ្ឋាភិបាលកម្ពុជា៖**

- អនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ជាពិសេស មាត្រា ៤៧ ដែលតម្រូវថាដំណើរការសវនាការ និងការប្រកាសសេចក្ដីសម្រេចត្រូវធ្វើឡើងជាអសាធារណៈ។
- អនុវត្តតាមការប្រតិបត្តិដ៏ល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអនុញ្ញាតឱ្យជនជាប់ចោទជាអនីតិជនបង្ហាញខ្លួនចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលនីតិវិធីព្រហ្មទណ្ឌទាំងអស់។
- កម្រិតការឃុំខ្លួនបណ្ដោះអាសន្នរបស់អនីតិជនចំពោះករណីពិសេសនៅពេលដែលគ្មានជម្រើសផ្សេងទៀត និងធានាថាក្នុងករណីបែបនេះគ្រប់វិធានការចាំបាច់ត្រូវបានអនុវត្តដើម្បីគោរពសិទ្ធិរបស់អនីតិជន។
- ធានាថាចៅក្រម និងព្រះរាជអាជ្ញាទទួលបានការបណ្ដុះបណ្ដាលជាក់លាក់ពាក់ព័ន្ធនឹងបញ្ហាទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់អនីតិជន។
- ពិនិត្យមើលជម្រើសផ្សេងទៀតចំពោះទោសដាក់ពន្ធនាគារសម្រាប់អនីតិជន និងអនុវត្តគោលការណ៍ណែនាំទាំងឡាយដែលផ្ដន្ទាទោសទាក់ទងនឹងអនីតិជនដោយយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់លើការស្ដារនីតិសម្បទាឡើងវិញ ជាជាងការផ្ដន្ទាទោសតែម្យ៉ាង។
- ពិនិត្យឡើងវិញនូវច្បាប់ដែលចូលជាធរមាន ដើម្បីធានាការអនុវត្តច្បាប់ទាំងនោះអនុលោមតាមបទដ្ឋានអន្តរជាតិស្ដីពីប្រព័ន្ធយុត្តិធម៌អនីតិជន ដោយក្នុងនោះរួមមានវិធានអង្គការសហប្រជាជាតិស្ដីពី បទដ្ឋានអប្បបរមាសម្រាប់ការអនុវត្តយុត្តិធម៌អនីតិជន និងគោលការណ៍ណែនាំរបស់មូលនិធិសហប្រជាជាតិដើម្បីកុមារសម្រាប់កំណែទម្រង់ផ្នែកច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

ព្រឹត្តិបត្រព័ត៌មានស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក លេខមុនៗ អាចរកបានគេហទំព័ររបស់ ម.ស.ម.ក (លេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ លេខ៦ លេខ៧ លេខ៨ លេខ៩ លេខ១០ លេខ១១ លេខ១២ និង លេខ១៣)។ លោកអ្នកក៏អាចអានរបាយការណ៍ប្រចាំឆ្នាំ២០១៨ របាយការណ៍ប្រចាំឆ្នាំ២០១៩ និងរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់យើង ស្ដីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" ដែលបានបង្ហាញពីរបកគំហើញសំខាន់ៗពីការសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

BY NC SA